# ការរួមសហការណ៏ជាមួយសាលារៀនរបស់ខ្ញុំ

ពេលលោកអ្នកជាមាតាបិតាមានកូនម្នាក់ ឬច្រើននាក់រៀនទៅតាមសាលារៀនប្រចាំទីក្រុង សាន់ឌីអេហ្គោ របស់យើង (SDCS) មានមធ្យោបាយជាច្រើនយ៉ាងដែលលោកអ្នកអាចរួមសហការណ៏ជាមួយកូនលោកអ្នកសិក្សាបានទៅតាមសាលារៀន។ ការស្រាវជ្រាវបង្ហាញឲ្យឃើញថា ពេលមាតាបិតារួមសហការណ៏ជាមួយសាលារៀន កូនរបស់គាត់ច្បាស់ជាមានការរីកចំរើនខាងផ្នែកសិក្សា និងផ្នែកសង្គម។ ក្រសួងអប់រំប្រចាំទីក្រុង សាន់ឌីអេហ្គោ លើកទឹកចិត្តលោកអ្នកណែនាំកូនសិក្សានៅតាមផ្ទះ និងសាលារៀន។ បើលោកអ្នកមានបំណងចង់ស្នាក់បំរើជាមួយសាលារៀនប្រចាំក្រុង សូមពិនិត្យមើលទំព័រពត៌មាន ផ្នែកទាក់ទងមាតាបិតារបស់ក្រសួងអប់រំប្រចាំក្រុង www.sandi.net/comm/factsheets/index.html#9.

> **សង្ខេប**
>
> នេះជាសមាគមមួយចំនួនដែលមាតាបិតាអាចចូលរួមសហការណ៏ជាមួយសាលារៀនរបស់ខ្លួនបាន:
>
> - ក្រុមប្រឹក្សាប្រចាំសាលារៀន (SSC)
> - ក្រុមចាត់ចែងសាលារៀន (SGT)
> - គណៈកម្មការទីប្រឹក្សាសិស្សរៀន អង់គ្លេស (ELAC)
> - សមាគមទូទៅ
> - ទីប្រឹក្សាមាតាបិតាប្រចាំក្រសួងអប់រំ - សមាគមគ្រូ (PTA)
> - ក្រុមប៉ូលិសសាលារៀនស្នាក់យាមល្បាត (SPVP)
> - កម្មវិធីស្នាក់បំរើដល់សាលារៀន

**ក្រុមប្រធានទីប្រឹក្សាកំរិតសាលារៀន:**

- **ទីប្រឹក្សាសាលារៀន (SSC)**

SSC ជ្រើសរើសឡើងដោយក្រុមធ្វើការសម្រេចចិត្តដែលមានសមាជិកដូចជា: មាតាបិតា, សមាជិកសហគមន៍, អភិបាលប្រចាំសាលារៀន, លោកគ្រូ-អ្នកគ្រូ និងបុគ្គលិកផ្សេងៗ។ នៅតាមកំរិតមធ្យមសិក្សាមានសិស្សចូលរួមផងដែរ។ នេះជាឱកាសសំរាប់មាតាបិតាសិស្សបញ្ចេញសំឡេងឲ្យគេឯងបានដឹង។ SSC ទទួលការគ្រប់គ្រងផ្នែកបណ្តុះបណ្តាល, ប្រតិបត្តិ, ពិនិត្យ និងអោយតម្លៃទៅគម្រោងការសិក្សា។ សាលារៀនដែលមានកម្មវិធី Title I, SSC ធ្វើការពិនិត្យទៅលើផ្នែកថវិការទាំងអស់ដូចជា: កម្មវិធី Title I , ភាសាទី ពីរ, GATE។ ចាប់ពីឆ្នាំសិក្សា២០០៣ សាលារៀនទាំងអស់ត្រូវតែមាន SSC ដើម្បីទទួលថវិការ Title I ។ ពត៌មានបន្ថែម ចូរទាក់ទងចាងហ្វាង ឬប្រធាន SSC ដោយបើកប្រព័ន website មើល: http://www.sandi.net/saa/accountability/SSC/index.asp.

- **ក្រុមគ្រប់គ្រងសាលារៀន (SGT)**

តួនាទីរបស់ក្រុម SGT រៀបចំឡើង និងប្រតិបត្តិតាមយុទ្ធវិធីដ៏មានប្រសិទ្ធិភាពដើម្បីពង្រឹងការសិក្សាសិស្សអោយបានសម្រេចតាមជំនាញការបង្រៀនរបស់គ្រូៗនៅតាមសាលារៀននិមួយៗ។ ក្រុម SGT គឺជាក្រុមគោលការរបស់សាលារៀន, ក្រុមសម្រេចលើកិច្ចការសាលារៀនដែលបង្កើតឲ្យមានកិច្ចព្រមព្រៀងគ្នារវាងសាលារៀនប្រចាំក្រុងសាន់ឌីអេហ្គោ (SDCS) ព្រមទាំងសមាគមអប់រំប្រចាំ សាន់ឌីអេហ្គោ (SDEA)។ ផ្អែកក្រុងត្រាមួយរបស់ SDEA, ក្រុម SGT ត្រូវតែមានសមាជិកចូលរួមចំនួន ៥០ភាគរយ ហើយពី SDEA ៣៥ភាគរយ ឬយ៉ាងហោចណាស់ មាន មាតាបិតា/សមាជិកសហគមន៍ បីនាក់ និង១៥ភាគរយពីផ្នែកផ្សេងៗដែលមានរួមនឹងសមាគមបុគ្គលិកធ្វើការសាលារៀនប្រចាំ កាលីហ្វ័រញ៉ា (CSEA) ជាតំណាង និងសិស្សសាលាមធ្យមសិក្សា។ ពត៌មានបន្ថែម សូមទាក់ទង ចាងហ្វាងសាលារៀន ឬប្រធាន SGT ។

- **គណៈកម្មការទីប្រឹក្សាសិស្សរៀន អង់គ្លេស (ELAC)**

បើសាលារៀនរបស់លោកអ្នកមានសិស្សចំនួនលើសពី ២១នាក់ គេតម្រូវឲ្យមានក្រុម ELAC ដែលមានសមាជិកដូចជា មាតាបិតាសិស្សរៀន អង់គ្លេស, សមាជិកសហគមន៍, និងបុគ្គលិកសាលារៀនដែលផ្តល់ការណែនាំដល់ចាងហ្វាងស្តីអំពី កម្មវិធីបង្រៀនសិស្សរៀនអង់គ្លេស ព្រមទាំងការបំរើទូទៅនៅតាមសាលារៀន។ ELAC អាចធ្វើការស្នើសុំពត៌មានទៅ SSC ស្តីអំពី កម្មវិធី ELAC ព្រមទាំងការប្រើប្រាស់ថវិការផងដែរ។ បើលោកអ្នកមានសំនួរអ្វីមួយ សូមទាក់ទងចាងហ្វាងសាលារៀនរបស់លោកអ្នក ឬប្រធាន ។ ពត៌មានបន្ថែម ចូរបើកមើលលិខិតពត៌មាន ELAC នៅតាមប្រព័ន៍អ៊ីនធឺណែត: htt://www.sandi.net/comm/factsheets/englearners.pdf.

- **សមាគម**

ចូរសរសេរប្រយោគមួយឃ្លារៀបរាប់អំពី សកម្មភាពដែលសមាគមបានទទួលថវិការ ឬនឹងបានទទួលថវិការដូចជា: ថវិការតូចតាចសំរាប់គ្រូ, កម្មវិធីធ្វើដំណើរក្នុងការសិក្សា អាហារូបករណ៍, កម្មវិធីបង្រៀបន្ថែម។ល។ ចូរពន្យល់តម្លៃប្រចាំឆ្នាំ, ថវិការប្រចាំឆ្នាំ។ល។ ជាញឹកញ៉ាប់ សមាគមត្រូវបានចុះឈ្មោះតាមច្បាប់សមាគមមិនយកកម្រៃក្រោមមាត្រាលេខ 501(c)(3) ដែលជួយរកថវិការដាក់សាលារៀន។ ក្រសួងផ្នែកទំនាក់ទំនងសហគមន៍នៅជាប្រចាំការដើម្បីជួយដល់សាលារៀនដែលមានបំណងចង់បង្កើតឲ្យមានសមាគម។ ពត៌មានបន្ថែម ចូរទាក់ទងចាងហ្វាងប្រចាំសាលារៀន ឬប្រធានសមាគម។

**Janet D. Delaney,** បុគ្គលិកទាក់ទង (៦១៩) ៧២៥-៥៥៩៣ jdelaney@sandi.net

-បន្ត-

• **ទីប្រឹក្សាមាតាបិតាប្រចាំក្រសួងអប់រំ - សមាគមគ្រូ (PTA)**

គោលការណ៍សំខាន់របស់សមាគម PTA គឺជួយពង្រឹងសុខមាភាពសិស្សអោយល្អនៅតាមផ្ទះ, សាលារៀន និងសហគមន៍។ ចូររៀបរាប់អំពី គោលការប្រចាំឆ្នាំរបស់សមាគម PTA , សកម្មភាព និងកម្មវិធីទូទៅ និងរបៀបប្រមូលគ្នានៅតាមសាលារៀនដើម្បីពង្រឹងកម្មសិក្សានៅតាមសាលារៀនអោយបានល្អតលាស់។ ពត៌មានបន្ថែមសូមទូរស័ព្ទចាងហ្វាងប្រចាំសាលារៀនរបស់លោកអ្នក, ប្រធាន ឬការិយាល័យទីប្រឹក្សាក្រសួងអប់រំប្រចាំក្រុងលេខ (៦១៩) ២៩៧-៧៨២១ ។ ចូរពិនិត្យមើលប្រព័ន website របស់សមាគម PTA ជាតិ: htt://www.pta.org/.

**Debbie Vincent,** ប្រធាន (៦១៩) ២៩៧-៧៨២១ bzydeb@san.rr.com

**ទីប្រឹក្សាមាតាបិតាប្រចាំក្រសួងអប់រំ - សមាគមគ្រូ**

• **ក្រុមប៉ូលីសសាលារៀនស្នាក់យាមល្បាត (SPVP)**

ក្រុម SPVP មានសមាជិកដូចជា: មាតាបិតាស្នាក់បំរើ និងសមាជិកសហគមន៍ពាក់អាវកាកពណ៌ក្រូចភ្លឺ និងស្អតពណ៌លឿងការពារ និងមានវិទ្យុទាក់ទងគ្នាជាមួយអភិបាលសាលារៀន និងភ្នាក់ងារប៉ូលីសបំរើសហគមន៍។ រៀនរាល់ថ្ងៃចំនួន ៤៥នាទី មុនពេលសិស្សចូលរៀនសាមសិបនាទី និងក្រោយពេលសិស្សចេញទៅផ្ទះសាមសិបនាទី ក្រុម SPVP ជួយយាមល្បាតការពារសន្តិសុខនៅតាមផ្លូវក្បែរចិញ្ចើមថ្នល់មុខសាលារៀន និងផ្លូវក្បែរសាលារៀន។ បន្ថែមពួកគេកត់លេខផ្លាកឡានណាដែលបើកលឿនហួសហេត ហើយរាយការណ៍ឡើងទៅប៉ូលីសសាលារៀន ដើម្បីសរសេរលិខិតប្រមាន ឬពិន័យ។ មុនមាតាបិតា និងសមាជិកសហគមន៍អាចធ្វើការស្នាក់បំរើជាមួយក្រុមប៉ូលីសសាលារៀនស្នាក់យាមល្បាត (SPVP)បាន គេតម្រូវអោយបំពេញពាក្យស្នើសុំដែលមាននៅតាមប្រព័ន online at: http://www.sandi.net/pdf/comm_ntbk.pdf ទំព័រ ៨០ ហើយយល់ព្រមអោយគេឆែកមើលប្រវត្តិរូបផងដែរ។ ការឆែកនេះមានរួមដូចជាការឆែកពិនិត្យមើលប្រវត្តិរូបបទឧក្រិដ្ឋកម្មតាមកុំព្យូទ័រ និងពិគ្រោះជាមួយច្បាប់ Megan ។ ពត៌មានបន្ថែមសូមពិនិត្យ មើលប្រព័ន website at: http://prod031.sandi.net/policeservices/.

**ការបំរើរបស់ក្រសួងប៉ូលីសប្រចាំសាលារៀន (៦១៩) ៧២៥-៧០០០**

• **កម្មវិធីស្នាក់បំរើដល់សាលារៀន**

សាលារៀនប្រចាំទីក្រុង សាន់ឌីអេហ្គោ ទទួលផលប្រយោជន៍ពីអ្នកស្នាក់បំរើសហគមន៍ ជាង ២៣០០០នាក់ រួមទឹង មាតាបិតា, ហាងជំនួញ/សហគមន៍ជាដៃគូ, សមាជិកសហគមន៍, ជនវ័យចំណាស់?, សិស្សមហាវិទ្យាល័យ និងសិស្សរបស់យើងផ្ទាល់។ ឆ្នាំកន្លងទៅនេះការស្នាក់បំរើដល់សាលារៀនមានចំនួនជាង ៦៥០០០ម៉ោង។ សកម្មភាពនៃការស្នាក់បំរើមានរួមទឹងការបង្រៀន, ការពិនិត្យពិចៃ, ការរៀនអានអោយបានឮខ្លាំងដល់សិស្សស្តាប់, ការជួយនៅតាថ្នាក់រៀន, ការចូលរួមជាមួយសមាគមសាលារៀនដូចជា: សមាគម PTA, SSC , ការជួយនៅតាមបណ្ណាល័យ/មជ្ឈមណ្ឌល, ជួយនៅតាមសាលារៀន/បន្ទប់រៀនសិស្ស, ជួយក្នុងកម្មវិធីក្រោយពេលសិស្សចេញទៅផ្ទះ, ជួយដល់ការយាមល្បាត។ល។ សាលារៀនអាចកត់ត្រាក្នុងបញ្ជីនូវសេចក្តីត្រូវការក្នុងការស្នាក់បំរើ។ សាលារៀននិមួយៗចាត់តាំងឲ្យមានបុគ្គលិកម្នាក់សំរាប់ណែនាំដល់បុគ្គលិកស្នាក់បំរើដើម្បីជួយតាមសេចក្តីត្រូវការរបស់បុគ្គលិកស្នាក់បំរើ។ ពត៌មានបន្ថែម ចូរទាក់ទងចាងហ្វាងប្រចាំសាលារៀន, បុគ្គលិកចាត់ចែងបុគ្គលិកស្នាក់បំរើ, បុគ្គលិកទាក់ទងមាតាបិតា (PAL) ឬទាក់ទងសហគមន៍។ ចូរបើកប្រព័ន website មើល: htt://www.sandi.net/partnersPIE Volunteer Program/htm.

**Ellen Tiffany,** បុគ្គលិកទាក់ទង (៦១៩) ៧២៥-៥៥៩៤ etiffany@mail.sandi.net

បោះពុម្ភដែលមានការគាំទ្រពីសមាគម Annie E.Casey



ការបំរើសិស្សជាង ១៣៨០០០នាក់, សាលារៀនប្រចាំទីក្រុង សាន់ឌីអេហ្គោ គឺជាសាលារៀនប្រចាំក្រុងធំទី ពីរ ក្នុងចំណោមសាលារៀនទាំងអស់នៅក្នុងរដ្ឋ កាលីហ្វ័រញ៉ា ដែលមានមណ្ឌលចំនួនជាង ២០០ ព្រមទាំងបុគ្គលិកចំនួន ១៤៥០០នាក់ធ្វើការពេញម៉ោង (តំណាងបុគ្គលិកជាង ១៨៨០០នាក់)។ SDCS ពង្រឹងការអប់រំសិស្សតាមជំនាញគោលការអប់រំផ្នែក រៀនអាន, សរសេរ និងគណិតសាស្ត្រ។ ក្រសួងអប់រំប្រចាំក្រុងផ្តាច់ញ៉ាំគាំទ្រសាលារៀន និងបង្កើនបរិយាកាសដល់សិស្សសិក្សានៅតាមបន្ទប់រៀនដោយកែប្រែមណ្ឌលសិក្សា និងទទួលប្រភពពត៌មានទូទៅ និងតាមមាតាបិតាសិស្ស, ការទាក់ទងពីលោកគ្រូ-អ្នកគ្រូ និងសហគមន៍តាមរបៀបអប់រំ។

" បេសកកម្មរបស់ក្រសួងអប់រំប្រចាំទីក្រុង សាន់ឌីអេហ្គោ គឺពង្រឹងការសិក្សាសិស្សឲ្យបានសម្រេច ដោយគាំទ្រការបង្រៀនរបស់លោកគ្រូ-អ្នកគ្រូ ព្រមទាំងការសិក្សារបស់សិស្សនៅតាមបន្ទប់រៀន។ "

Getting Involved at My School. Cambodian.